**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាខេត្តកែប**

លេខ៤១០.ស.ជ.ណ/ខក

កែប, ថ្ងៃទី៣០.ខែកញ្ញា.ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦

អភិបាលនៃគណៈអភិបាលខេត្តកែប មានកិត្តិយសសូមជម្រាបជូនដំណឹង ដល់អ្នកទទួលការទាំងអស់ដែលមានបំណងដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦ ឱ្យបានជ្រាបថា សាលាខេត្តកែបនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំថ្មី សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង... ។ល ។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម... ។ល ។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់... ។ល ។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទង នឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើល **គុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តទាន់ពេលវេលា** និង**កិច្ចសហប្រតិបត្តិការ**របស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកទំនាក់ទំនងដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និង វិនិយោគសាលាខេត្ត នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ **ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ វេលាម៉ោង ៥ : ៣០នាទីល្ងាច**។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំ២០១៥ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគសាសាខេត្ត ដោយឥតបង់ថ្លៃ តាមអាស័យដ្ឋានអគារ ផអ៣ (អតីតអគារ គ.ប្រ) ក្នុងបរិវេណសាលាខេត្តកែប ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប ។

**អភិបាលខេត្ត**

**កែន.សត្ថា**

<u>ចម្លងជូន</u>

-លេខាធិការដ្ឋាន គ.ជ.អ.ប
-ក្រុមប្រឹក្សាខេត្ត
(ដើម្បីជូនជ្រាប)
-ឯកសារ